# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាសម្ពោធព្រះវិហារថ្មី
# ជុំគិរី ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩
# យើងជាព្រះដំណាក់របស់ព្រះជាម្ចាស់

**អត្ថបទទី១៖ នេហេមី ៨,១-១០**

ពេលប្រជាជនទាំងមូលឮព្រះបន្ទូល ដែលមាននៅក្នុងគម្ពីរវិន័យពួកគេនាំគ្នាយំ។ នហ ៨,៩

**អត្ថបទទី២៖ កូរិនថូសទី១ ៣,៩-១១.១៦-១៧**

បងប្អូនមិនជ្រាបថាខ្លួនជាព្រះវិហាររបស់ព្រះជាម្ចាស់ទេឬ! បងប្អូនមិនជ្រាបថាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សណ្ឋិតនៅក្នុងបងប្អូនទេឬ។ ១ករ ៣,១៦

**ដំណឹងល្អ៖ យ៉ូហាន ៤,១៩-២៤**

ព្រះជាម្ចាស់ជាវិញ្ញាណ ហេតុនេះអស់អ្នកដែលថ្វាយបង្គំព្រះអង្គត្រូវតែថ្វាយបង្គំតាមវិញ្ញាណ និងតាមសេចក្ដីពិត។ យហ ៤,២៤

បងប្អូនជាទីស្រឡាញ់!

នៅក្នុងអត្ថបទទី១ មានលោកបណ្ឌិតគម្ពីរទៅកន្លែងពិសេសលើអាសនៈដើម្បីប្រកាសអំពីគម្ពីរ អំពីធម្មវិន័យ ណែនាំឲ្យប្រជាជនទាំងអស់គេយំ។ នៅពេលគេយំអស់ហើយគេបានថ្លែងថា "**ថ្ងៃនេះជាថ្ងៃដ៏សក្ការៈថ្វាយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា គឺមិនមែនជាពេលដែលត្រូវកាន់ទុក្ខឬសោកសង្រេងឡើយ**"។ ថ្ងៃនេះ ជាថ្ងៃដែលយើងពោរពេញដោយអំណរសប្បាយ ជាថ្ងៃដែលយើងពោរពេញដោយចិត្តចង់កោតសរសើរព្រះជាម្ចាស់ អរព្រះគុណព្រះជាម្ចាស់។ ថ្ងៃនេះ ព្រះសហាគមន៍របស់យើងបានទទួលព្រះវិហារថ្មី សូមអរគុណលោកឪពុកនិងបងប្អូនទាំងអស់ ដែលបានជួយឧបត្ថម្ភដែលចេញកម្លាំងកាយកម្លាំងចិត្ត ដើម្បីសាងសង់ព្រះវិហារដ៏ថ្មីនេះ។ខ្ញុំជឿថា មីងអាន និងគ្រីស្ដបរិស័ទនៅទីនេះ សប្បាយចិត្តណាស់រង់ចាំថ្ងៃនេះយូរហើយ ចាំព្រះវិហារយូរហើយ ដើម្បីរួមគ្នាមកព្រះវិហារ។ ស្ដាប់អត្ថបទគម្ពីរ "**កន្លែងដែលត្រូវថ្វាយបង្គំគឺមិនមែននៅលើភ្នំមិនមែននៅវិហារយេរ៉ូសាឡឹម ប៉ុន្តែសំខាន់បំផុតឲ្យយើងចេះថ្វាយបង្គំតាមវិញ្ញាណ និងតាមសេចក្ដីពិត**"។

ព្រះវិហាររបស់យើង ជាកន្លែងមួយដែលយើងជួបជុំគ្នាដើម្បីថ្វាយបង្គំដល់ព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើង និងដើម្បីរស់នៅក្នុងជីវិតរបស់យើងជាប្រចាំតាមព្រះទ្នូល។ មានន័យថា រស់នៅតាមព្រះយេស៊ូគ្រីស្ដដែលជាសេចក្ដីពិត ដែលណែនាំឲ្យជីវិតរបស់យើងពោរពេញដោយសេចក្ដីសុខ និងជាពិសេសឲ្យជីវិតរបស់យើងមានពន្លឺមួយដែលណែនាំឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត។ នៅទីនេះយើងក្រុមស្ត្រីច្រើនណាស់ នេះសេចក្ដីសង្ឃឹមនិងជាកម្លាំងសម្រាប់

ព្រះសហគមន៍យើង ពួកគាត់មកទីនេះដោយសារព្រះសហគមន៍យើងជាកន្លែងមួយ ដែលគាត់រកឃើញការស្វាគមន៍យ៉ាងកក់ក្តៅ។ ព្រះសហគមន៍របស់យើងមិនមែនគ្រាន់តែជាព្រះវិហារ ក៏ប៉ុន្តែព្រះសហគមន៍របស់យើងត្រូវតែជាព្រះដំណាក់ "**យើងជាព្រះដំណាក់របស់ព្រះជាម្ចាស់**"។ ព្រះដំណាក់ដែលស្វាគមន៍ជានិច្ច ព្រះដំណាក់ដែលកក់ក្តៅ ព្រះដំណាក់ដែលនៅពេលយើងមកដល់ទីនេះយើងមានអារម្មណ៍ថាយើងមិនមែនជាសាសន៍ដទៃ យើងមិនមែនជាមនុស្សផ្សេង ប៉ុន្តែយើងចូលនៅក្នុងកន្លែងមួយដែលយើងយល់ថាគេស្វាគមន៍យើង យើងកក់ក្តៅនៅក្នុងចិត្តរបស់យើង យើងនិយាយភាសាតែមួយ យើងយល់ចិត្តគ្នា យើងស្តាប់គ្នាបាន។ ដោយសារកន្លែងនេះជាកន្លែងមួយដែលទទួលស្វាគមន៍គ្រួសារដ៏កក់ក្តៅ គ្រួសារដែលចេះស្រឡាញ់ គ្រួសារដែលធ្វើដំណើរជាមួយគ្នា។

ព្រះវិហាររបស់យើង ជាកន្លែងមួយដែលជួបជុំគ្នាដែលយើងយល់ថាយើងកក់ក្តៅ យើងសប្បាយចិត្តជួបជុំគ្នាដោយសារយើងរកឃើញបងប្អូនដែលជាគ្រួសាររបស់យើង ដែលចេះរស់នៅជាមួយគ្នា ដែលចេះស្តាប់គ្នា ដែលចេះយល់ចិត្តគ្នាដើម្បីធ្វើដំណើរជាមួយគ្នា។

ព្រះដំណាក់របស់ព្រះជាម្ចាស់ ជាកន្លែងមួយដែលយើងមកដើម្បីសម្រាកនៅក្បែរព្រះយេស៊ូ យើងមានទូព្រះកាយព្រះគ្រីស្តយើងមានវត្តមានរបស់ព្រះយេស៊ូផ្ទាល់។ ពេលថ្ងៃក្តៅយើងអាចមកព្រះវិហារនេះដើម្បីសម្រាក មិនមែនដេកតែសម្រាកឲ្យត្រជាក់នៅក្បែរព្រះយេស៊ូមានន័យថាមកអង្គុយអធិដ្ឋាន។ ព្រះវិហារយើង ជាកន្លែងមួយដែលបើកទ្វាររហូត ជាកន្លែងមួយដើម្បីសម្រាកនៅក្បែរព្រះយេស៊ូ ជាកន្លែងមួយដែលអង្គុយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប៉ុន្តែ មិនមែនតែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ស្តាប់ផងនិងចែករំលែកអំពីព្រះបន្ទូលដែលយើងស្តាប់ផង ដើម្បីនឹកឃើញតើព្រះបន្ទូលនេះមានអត្ថន័យអ្វីខ្លះសម្រាប់ជីវិតខ្ញុំ? រាល់ថ្ងៃយើងអានព្រះគម្ពីររួមគ្នា យើងត្រូវការគិតព្រះបន្ទូលមានអត្ថន័យអ្វីសម្រាប់ជីវិតខ្ញុំ សម្រាប់គ្រួសារខ្ញុំសម្រាប់កូនខ្ញុំ សម្រាប់បងប្អូនខ្ញុំ។

ព្រះដំណាក់របស់ព្រះជាម្ចាស់ ទៅជាកន្លែងមួយដែលយើងអាចទទួលស្វាគមន៍ជាពិសេសបងប្អូនដែលជួបទុក្ខលំបាកនៅក្នុងជីវិត អ្នកក្រីក្រ អ្នកជំងឺ បងប្អូនដែលអត់មានសេចក្តីសង្ឃឹមនៅក្នុងជីវិត បងប្អូនដែលអត់មានផ្លូវដើម្បីធ្វើដំណើរទៅរកពន្លឺនៅក្នុងជីវិត។ ព្រះដំណាក់របស់ព្រះជាម្ចាស់ ជាកន្លែងមួយដែលបងប្អូនទាំងអស់នៅតាមផ្លូវដឹងថា យើងអាចឈប់បានដើម្បីរកឃើញសេចក្តីសង្ឃឹម។ ក្នុងភូមិភាគភ្នំពេញមណ្ឌលកំពត ព្រះសហគមន៍បានយកចិត្តទុកដាក់និងថែរក្សាអ្នកជំងឺដើម្បីណែនាំឲ្យគេបានទទួលការព្យាបាលច្រើន។ ព្រះសហគមន៍យើង ជាកន្លែងមួយពិសេសដែលទទួលស្វាគមន៍អ្នកជំងឺ អ្នកក្រីក្រ អ្នកដែលគ្មានទីពឹង អ្នកដែលរស់នៅ

ក្នុងជីវិតកំសត់ទុរគត ឲ្យកន្លែងនេះជាកន្លែងដែលគេអាចសម្រាកបាន។ ព្រះសហគមន៍នេះ ជាព្រះសហគមន៍មួយដែលប្លែក សម័យលោកវីរជ័យ លោកលី លោកសុន យើងមានយុវជនយុវនារីច្រើនណាស់ សព្វថ្ងៃយើងមានមីងៗមួយចំនួនធំ និងមានកូនក្មេងដែរ។ ដូច្នេះ កន្លែងនេះជាកន្លែងមួយដែលយើងមកជួបជុំគ្នាគ្រប់ជំនាន់ កូនក្មេង យុវជនយុវនារី មីង យាយ ដូច្នេះនេះជាឱកាសមួយដើម្បីចែករំលែកបទពិសោធន៍នៅក្នុងជីវិត។

ព្រះដំណាក់របស់ព្រះជាម្ចាស់ ទៅជាកន្លែងមួយដែលយើងអាចស្តាប់គ្នាទៅវិញទៅមក មើលកូនក្មេងផង យុវជនផង មីងពូឪពុកម្តាយលោកតាលោកយាយផង ដើម្បីចែករំលែកបទពិសោធន៍នៃជីវិត ដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីធ្វើដំណើរជាមួយគ្នា ដើម្បីគោរពគ្នាទៅវិញទៅមកដោយដឹងថាពិតមែនក្នុងដំណាក់ព្រះជាម្ចាស់ជាគ្រួសារមួយយ៉ាងពិសេស។

ព្រះដំណាក់របស់ព្រះជាម្ចាស់ ជាព្រះដំណាក់មួយដែលយើងត្រូវតែបើកទ្វារ បើករបង បើកព្រះសហគមន៍របស់យើង ដោយដឹងថាបងប្អូនណាក៏យើងស្វាគមន៍ ពុទ្ធបរិស័ទក្តី គ្រីស្តបរិស័ទក្តី អ៊ីស្លាមបរិស័ទក្តី គេជាអ្នកក្រីក្រក្តី គេជាអ្នកមានក្តី។ ថ្ងៃនេះយើងសូមស្វាគមន៍អាជ្ញាធរដែនដី លោកប្រធាន លោកអនុប្រធានមន្ទីរ លោកប្រធានការិយាល័យធម្មការនិងសាសនា ដែលបានអញ្ជើញចូលរួមជាមួយយើង នេះជាសញ្ញាមួយដោយដឹងថានៅក្នុងភូមិយើងធ្វើដំណើរជាមួយគ្នា យើងជាគ្រួសារមួយយើងចេះគោរពគ្នាទៅវិញទៅមក យើងបើកទ្វារបើករបងដើម្បីទទួលស្វាគមន៍បងប្អូននៅក្នុងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់។

ឲ្យព្រះដំណាក់របស់ព្រះជាម្ចាស់នៅជុំគិរីនេះ ទៅជាកន្លែងមួយដើម្បីជប់លៀង ព្រះយេស៊ូមានសញ្ញាសម្គាល់ទី១ នៅមង្គលការក្នុងភូមិកាណាដោយធ្វើឲ្យទឹកក្លាយទៅជាស្រា ដើម្បីឲ្យមនុស្សដែលកំពុងជួបជុំគ្នានៅក្នុងអំណរសប្បាយ មើលឃើញសញ្ញាមួយយ៉ាងពិសេសអំពីវត្តមានរបស់ព្រះយេស៊ូ។ ជប់លៀង ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍មួយពោរពេញទៅដោយអំណរសប្បាយ ដូចយើងបានស្តាប់ "**ថ្ងៃនេះជាថ្ងៃដែលយើងថ្វាយបង្គំពិតមែនតែជាថ្ងៃដែលយើងពោរពេញដោយអំណរសប្បាយនៅក្នុងដួងចិត្តរបស់យើង**"។ យើងមានព្រះនាងម៉ារី ដែលបើកដៃដើម្បីទទួលស្វាគមន៍បងប្អូនជានិច្ច ព្រះនាងម៉ារីដែលច្រៀងកោតសរសើរព្រះជាម្ចាស់អស់ពីដួងចិត្ត "**ពិតមែនព្រះអង្គបានធ្វើការអស្ចារ្យសម្រាប់ខ្ញុំ ព្រះអង្គបានជ្រើសរើសខ្ញុំធ្វើជាមាតារបស់ព្រះអង្គ ព្រះអង្គបានលើកតម្កើងខ្ញុំពីជំនាន់មួយទៅជំនាន់មួយ**"។ ថ្ងៃនេះ យើងអាចនិយាយបានថាព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍សន្តយ៉ូសែបជុំគិរី បានធ្វើការអស្ចារ្យពិតមែន។ ព្រះជាម្ចាស់បានជ្រើសរើសជុំគិរី ដើម្បីធ្វើជាសញ្ញាសម្គាល់នៃជីវិតដ៏បរិបូណ៌ដែលមកពី

ព្រះយេស៊ូ ព្រះជាម្ចាស់បានជ្រើសរើសជុំគិរី ដើម្បីពោរពេញដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់ពីជំនាន់មួយទៅជំនាន់មួយទៀត។ អាម៉ែន៕